00647772

E9/14

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | 00២/១៩-0៩-២00៧-អវតក/អជសង |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមពេលសម្រាប់ដាក់អញ្ញត្រកម្ម**

**ទៅនឹង សាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និង អ្នកជំនាញដែលបានស្នើដោយភាគីនានា**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | **នួន ជា** |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | **អៀង សារី** |
| | ចៅក្រម យ៉ា សុខន | **អៀង ធីរិទ្ធ** |
| | ចៅក្រមJean-Marc LAVERGNE | **ខៀវ សំផន** |
| | ចៅក្រម ធូ មណី | |
| | | **មេធាវីការពារក្ដីជនជាប់ចោទ:** |

**ឯកសារដើម** (stamp)
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 24 / 02 / 2011
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសម*

E9/14

| | |
|---|---|
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | លោក សុន អរុណ |
| | លោក Michiel PESTMAN |
| ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |
| | លោក Phillipe GRECIANO |

# I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាសូមស្នើថា កាលបរិច្ឆេទកំណត់សម្រាប់ដាក់អញ្ញត្រកម្មទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកជំនាញដែលបានស្នើដោយភាគីនានា ពន្យារដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ ២០១១ ។

# II. សាវតារ និង ដោះឆោះស្រាយដែលស្វែងរក

២. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញរបស់ខ្លួន ដោយអនុលោមតាមវិធាន៨០.១ នៃវិធានផ្ទៃក្នុង និងដោយស្របតាម*ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ("ដីកាបង្គាប់")*[1]។ ភាគីដទៃទៀតបានទទួលការជូនដំណឹងពីការដាក់ឯកសារនេះនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ។ អនុលោមតាមអនុវិធាន៨០.២ ពួកគាត់ត្រូវបានតម្រូវឱ្យដាក់បញ្ជីឈ្មោះសាក្សីនានារបស់ពួកគាត់ ដែលបានស្នើក្នុងរយៈពេលចំនួន១៥ថ្ងៃ គិតពីការជូនដំណឹងនូវបញ្ជីឈ្មោះរបស់សហព្រះរាជអាជ្ញា ដែលមានកាលបរិច្ឆេទកំណត់នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១១ ។

៣. កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១១ សហព្រះរាជអាជ្ញាបានទទួលនូវបញ្ជីឈ្មោះអ្នកជំនាញដែលបានស្នើសុំមួយរបស់ អៀង សារី (ដែលមានអ្នកជំនាញ៥រូប)[2] ហើយកាលពីថ្ងៃទី១៥ ខែកុម្ភៈ សហព្រះរាអាជ្ញាបានទទួលនូវៈ ១) បញ្ជីឈ្មោះអ្នកជំនាញចំនួន១៣រូប របស់ នួន ជា, និងចំនួន៥រូប (ដែលក្រោយមកកើនឡើងដល់ ៦រូប) របស់ដើមបណ្តឹងរដ្ឋប្បវេណី[3] ២) បញ្ជីឈ្មោះសាក្សីរបស់ អៀង ធីរិទ្ធ (ដែលមានសាក្សីចំនួន៩រូប)[4] ៣) បញ្ជីឈ្មោះសាក្សី របស់ដើមបណ្តឹងរដ្ឋប្បវេណី (ដែលមានដើមបណ្តឹងរដ្ឋប្បវេណី ចំនួន១៤៦រូប, សាក្សីចំនួន១៨រូប, និងអ្នកជំនាញ១៥រូប)[5]

[1] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, ថ្ងៃទី១៧ មករា ២០១១, E9 ។ បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១, ទី២, ទី៣, ទី៣ក, ទី៤ និង ទី៥, ថ្ងៃទី២៨ មករា ២០១១, E9/4.1 ។

[2] បញ្ជីឈ្មោះអ្នកជំនាញដែលត្រូវបានស្នើសុំ របស់ អៀង សារី និងសេចក្តីជូនដំណឹងស្តីពីបញ្ជីឈ្មោះសាក្សី និងដើមបណ្តឹង, ចុះថ្ងៃទី១៤ កុម្ភៈ ២០១១, ឯកសារលេខ E9/4/2។

[3] បញ្ជីឈ្មោះសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានស្នើសុំ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ឯកសារលេខ E9/4/4។

[4] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ អៀង ធីរិទ្ធ, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ឯកសារលេខ E9/4/5។

[5] បញ្ជីឈ្មោះសាក្សី, អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី របស់មេធាវីនាំមុខនៃដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង ដែលក្នុងនោះរួមមាន ឧបសម្ព័ន្ធសំងាត់ទី១, ទី២ក, ទី២ខ, ទី៣ក, ទី៣ខ, និងទី៤, ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ឯកសារលេខ E9/4/3។

បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់ ខៀវ សំផន (ដែលមានសាក្សីចំនួន២៦រូប, អ្នកជំនាញ ៣២រូប)[6], និងបញ្ជីឈ្មោះសាក្សី របស់ នួន ជា (ដែលមានសាក្សីចំនួន៥២៧រូប)[7] ដែលនឹងអាចមានផ្តល់ជូនបានលុះត្រាតែរហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១១ ប៉ុណ្ណោះ។

៤. ចំនួនសរុបនៃសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយគូភាគី ដោយមិនរាប់បញ្ចូលពីខាងសហព្រះរាជអាជ្ញា គឺមានចំនួន៧៩៧ ។ តាមដីកាបង្គាប់ ភាគីទាំងអស់តម្រូវឱ្យដាក់សេចក្តីសង្ខេបសាក្សីរបស់ខ្លួន ត្រឹមថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ហើយបើគិតត្រឹមថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ នេះ សេចក្តីសង្ខេបទាំងនេះបានដាក់ជូនរួចរាល់អស់ហើយ។ សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១១ អៀង សារី បានស្នើសុំបន្ថែមពេលវេលាកំណត់ដើម្បីឆ្លើយតបនឹងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា[8]។ ទោះបីជាបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញាបានដាក់មុនបញ្ជីសាក្សីរបស់ភាគីដទៃទៀតក៏ដោយ ជនជាប់ចោទមានរយៈពេល១៥ថ្ងៃច្រើនជាងសហព្រះរាជអាជ្ញា ដើម្បីពិចារណា និងដាក់អញ្ញត្រកម្មរបស់ខ្លួន។

៥. ដោយគិតដល់ការយឺតយ៉ាវនៃការដាក់ជូនបញ្ជីសាក្សីរបស់ នួន ជា និង ខៀវ សំផន និងចំនួនសរុបនៃសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយគូភាគី គេមិនអាចធ្វើការត្រួតពិនិត្យដ៏មានអត្ថន័យណាមួយទៅលើបុគ្គលម្នាក់ៗដែលបានស្នើឡើង និងដាក់អញ្ញត្រកម្ម ត្រឹមថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១១ បានឡើយ។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាស្នើសុំពន្យារពេលកំណត់សម្រាប់ដាក់អញ្ញត្រកម្ម រហូតដល់ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១១។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១ | **លោក យ៉េត ចរិយា**<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | |

[6] បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញដែលត្រូវបានស្នើសុំ, ចុះថ្ងៃទី២១ កុម្ភៈ ២០១១, ឯកសារលេខ E9/4/6។

[7] ឧបសម្ព័ន្ធ ក: បញ្ជីឈ្មោះសាក្សីដែលត្រូវបានស្នើសុំ- ក្រុមមេធាវីការពារក្តីរបស់ នួន ជា, ចុះថ្ងៃទី២២ កុម្ភៈ ២០១១, ឯកសារលេខ E9/4/4.4។

[8] សំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមពេលវេលាដើម្បីដាក់ការជំទាស់ទៅលើសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញដែលបានស្នើឡើងដោយ កសព, ១៦ កុម្ភៈ ២០១១ ឯកសារលេខ E9/7។